**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ក្រសួងព័ត៌មាន
**MINISTRY OF INFORMATION**

លេខ...១១៣១........ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី...២១.....ខែ..សីហា..ឆ្នាំ..២០១៧

# ជម្រាបមក

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍ គ្រប់ប្រព័ន្ធ និងចាងហ្វាងកាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រ ទាំងអស់

**កម្មវត្ថុ:** ស្ដីពីការផ្សាយស្ប៉តពាណិជ្ជកម្មផលិតផលពាក់ព័ន្ធវិស័យសុខាភិបាលដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល និងការផ្សាយពាណិជ្ជកម្មថ្នាំសម្រាប់សត្វល្អិតគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម។

**យោង:** -ច្បាប់ស្ដីពីការគ្រប់គ្រងឱសថចុះថ្ងៃទី២៣ខែមិថុនាឆ្នាំ១៩៩៦។

-លិខិតលេខ៦៦៦អបស/ឱអបសចុះថ្ងៃទី១៨ខែសីហាឆ្នាំ២០១៧របស់ក្រសួងសុខាភិបាល។

តាមកម្មវត្ថុ និងយោងខាងលើ ក្រសួងព័ត៌មានសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍ ចាងហ្វាងកាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រទាំងអស់ជ្រាបថា កន្លងមក ក្រសួងព័ត៌មាន បានសង្កេតឃើញថា ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនបានយកចិត្តទុកដាក់អនុវត្តតាមការណែនាំរបស់ក្រសួងព័ត៌មានស្ដីពីការផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មដែលពាក់ព័ន្ធវិស័យសុខាភិបាល បានយ៉ាងល្អប្រសើរគួរជាទីមោទនៈ។ ទន្ទឹមនេះ ក៏នៅមានម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនទៀត នៅតែបន្តធ្វើការផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មផលិតផលពាក់ព័ន្ធវិស័យសុខាភិបាលដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ដដែលៗ ទោះបីមានការណែនាំពីក្រសួងព័ត៌មានជាច្រើនលើកច្រើនសារហើយក៏ដោយ។

ការផ្សព្វផ្សាយបែបនេះ ជាទង្វើល្មើសច្បាប់និងធ្វើឲ្យខាតបង់ថវិការបស់ប្រជាពលរដ្ឋហើយប៉ះពាល់ដល់សុខភាព និងអាចបណ្ដាលឲ្យបាត់បង់ជីវិតរបស់ប្រជាពលរដ្ឋដែលប្រើផលិតផល និងសេវាទាំងនោះពុំបានត្រឹមត្រូវតាមក្បួនខាតវេជ្ជសាស្ត្រ។

ដើម្បីជៀសវាងនូវការប្រព្រឹត្តកំហុសឆ្គងជាយថាហេតុនិងការប្រព្រឹត្តល្មើសច្បាប់ ក្រសួងព័ត៌មាន សូមធ្វើការណែនាំក្រើនរំលឹកជាចុងក្រោយដល់ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដូចខាងក្រោម៖

-រាល់ការផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មផលិតផលពាក់ព័ន្ធវិស័យសុខាភិបាលត្រូវមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល និង

-រាល់ការផ្សព្វផ្សាយស្ប៉តពាណិជ្ជកម្មថ្នាំសម្រាប់សត្វល្អិតដែលពាក់ព័ន្ធវិស័យកសិកម្មត្រូវមានច្បាប់អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន។

ដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធ-ផ្សព្វផ្សាយទាំងអស់សហការអនុវត្តសេចក្ដីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រីទទួលនូវការរាប់អានដ៏កក់ក្ដៅពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

**ចម្លងជូន**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងសុខាភិបាល
-ក្រសួងកសិកម្ម
-សមាគមវិទ្យុកម្ពុជា-សមាគមទូរទស្សន៍កម្ពុជា
-សមាគមអ្នកសារព័ត៌មាន
-ឯកសារ

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

លេខ [illegible] អបស/ឱអបស

ក្រសួងព័ត៌មាន
មកដល់ថ្ងៃទី ១៤.០៨.១៧
ម៉ោង ១៥:១៥
លេខ ១៣៥៣ ពម

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០១៧

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## គោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន

**កម្មវត្ថុ ៖** សំណើសុំជួយមានវិធានការណែនាំអគ្គនាយកទូរទស្សន៍គ្រប់ប៉ុស្តិ៍ និងអគ្គនាយកវិទ្យុគ្រប់ប៉ុស្តិ៍ទាំងអស់ មិនអនុញ្ញាតឲ្យទទួលការផ្សព្វផ្សាយផលិតផលពាក់ព័ន្ធវិស័យសុខាភិបាលដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល។

**យោង ៖**
- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- ប្រកាសលេខ ៣៥៣អ.ប.ស/ឱ.អ.ប.ស ចុះថ្ងៃទី០២-០៩-២០១៥របស់ក្រសួងសុខាភិបាល ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផលដែលមាន គុណភាពក្នុងការបង្ការឬ ព្យាបាលជំងឺ
- ប្រកាសរួមក្រសួងសុខាភិបាល និងក្រសួងព័ត៌មានចុះថ្ងៃទី ២១-០២-០៦ ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថសម័យ ឱសថបូរាណ គ្រឿងសំអាងផលិតផលសំរាប់ចិញ្ចឹមទារក-កុមារថ្នាំជក់ និងសេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងព័ត៌មានមេត្តាជ្រាបថាៈ រាល់ការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលឱសថ គ្រឿងសំអាង និងចំណីអាហារ ក្រុមហ៊ុនជាម្ចាស់ផលិតផលត្រូវមកសុំច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាលជាមុនសិន ទើបក្រុមហ៊ុនមានសិទ្ធិយកលិខិតអនុញ្ញាតនេះស្នើសុំអគ្គនាយកទូរទស្សន៍ និងអគ្គនាយកវិទ្យុដើម្បីធ្វើការផ្សព្វផ្សាយតាមខ្លឹមសារដែលបានអនុញ្ញាត ហើយការផ្សព្វផ្សាយនេះមិនអនុញ្ញាតឲ្យផ្សព្វផ្សាយបន្ថែមពាក្យពេចន៍ រូបភាព និងមធ្យោបាយផ្សេងទៀតក្នុងន័យកែឆ្នៃខុសពីអត្ថបទដើមដែលក្រសួងបានអនុញ្ញាតជូនឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូម **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងព័ត៌មាន មេត្តាជួយមានវិធានការណែនាំដល់អគ្គនាយកទូរទស្សន៍គ្រប់ប៉ុស្តិ៍ និងអគ្គនាយកវិទ្យុគ្រប់ប៉ុស្តិ៍តាមបណ្តារាជធានីខេត្តទាំងអស់មិនអនុញ្ញាតឲ្យទទួលការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលឱសថ គ្រឿងសំអាង និងចំណីអាហារ របស់ក្រុមហ៊ុនណាដែលគ្មានច្បាប់អនុញ្ញាតឲ្យផ្សព្វផ្សាយពីក្រសួងសុខាភិបាលឡើយ។

ក្រសួងសុខាភិបាលសង្ឃឹមថា **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងព័ត៌មាន នឹងមានវិធានការណែនាំដល់អគ្គនាយកទូរទស្សន៍គ្រប់ប៉ុស្តិ៍និងវិទ្យុគ្រប់ប៉ុស្តិ៍ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យអនុវត្តតាមការណែនាំនេះតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងព័ត៌មាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ចម្លងជូនៈ**
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-លេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី ខេត្ត លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
-គ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់ (ដើម្បីជ្រាបជាព័ត៌មាន និងសហការ)
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល

**ម៉ម_ប៊ុនហេង**